សួស្តីមិត្តភក្តិទាំងអស់គ្នា ជួបជាមួយខ្ញុំម្តងទៀតហើយនៅក្នុងការបកស្រាយប្រធានបទ បាទ ម្ហូបហឹរ។ បាទ ដូច្នេះកុំឲ្យខាតពេលយូរ ខ្ញុំសូមបកស្រាយនូវប្រធានបទមួយនេះតែម្តង បាទ ម្ហូបហឹរ បាទ គឺថាយើងអាស្រ័យទៅលើមនុស្សធំ ឬមួយក៏កូនក្មេង។ បាទ កូនក្មេងភាគច្រើន បាទ គឺគេមិនសូវចូលចិត្តម្ទេសទេ ព្រោះថាម្ទេសគឺធ្វើឲ្យគេក្តៅមាត់ បាទ ក្តៅដល់អណ្តាតរបស់គេ ហើយគេពិបាកទ្រាំ បាទ យើងដឹងហើយថាកូនក្មេងគឺវាមិនសូវចេះទ្រាំប៉ុន្មានទេ អារឿងហឹរ អារឿងឈឺ អារឿងស្អីនឹងវាមិនសូវជាទ្រាំបានប៉ុន្មានទេ។ បាទ ពេលដែលឧទាហរណ៍ថាមនុស្សចាស់ ដូចថាយើងអញ្ចឹង [...] ពេលដែលដាំស្លម្តងៗ អញ្ចឹង យើងមិនតម្រូវចិត្តយើង បាទ យើងមិនមែនតម្រូវចិត្តក្មេងណា ឧទាហរណ៍ថាសម្លអីអញ្ចឹងទៅ សម្លម្ជូរ ដូចថាសម្លម្ជូរអញ្ចឹងទៅ ញោច គាត់ញោចម្ទេសចូលទៅក្នុងសម្លហ្នឹង។ បាទ ពេលដែលគាត់ញោចម្ទេសចូលទៅក្នុងសម្លអញ្ចឹង ហើយត្រូវយើងនឹងញុាំម្ទេសនឹងដែរ បាទ ត្រូវយើងនឹងញុាំម្ទេសនឹងដែរ [អញ្ចឹងទៅ?] ធ្វើឲ្យយើងនឹងក្តៅមាត់ បាទ ហើយចាស់ៗគាត់ចេះតែថាឲ្យកូនក្មេង [...?] គ្រាន់តែម្ហូបប៉ុណ្ណឹងក៏មិនសូវចេះញុាំដែរ។ បាទ ព្រោះថាកូនក្មេងគឺវាមានស្បែកខ្ចី កាលណាដែលស្បែកខ្ចីគឺញុាំហឹរ [...?] គឺអត់បានទេ។ បាទ ចេញទឹកភ្នែក ចេញទឹកសំបោរ បាទ កាលនៅពីក្មេងអីអញ្ចឹង ក្មេងៗ បាទ ហើយក្មេងគឺ ពេលដែលញុាំបាយអញ្ចឹងទៅ កាលណាគ្នាមិនសូវជាទ្រាំបានទេ ព្រោះថាបាយក៏ក្តៅ ម្ហូបក៏ក្តៅ បាទ ពេលដែលក្តៅអញ្ចឹងទៅ ភាគច្រើនគឺកូនក្មេងនឹងយំ បាទ យំ គឺយំ។ [...?] កូនក្មេងខ្លះគឺវាដល់ថ្នាក់ទៅវាអត់ញុាំម្ហូបនឹងទៀតផង ព្រោះថាវាញុាំអត់បានណា បាទ ព្រោះថាវាញុាំអត់បាន វាមានលក្ខណៈហឹរពេក បាទ ហើយកាលណាវាទៅស្រូបបាយ ស្រូបបាយញុាំជាមួយទឹកត្រី ឬមួយក៏ទឹកស៊ីអ៊ីវអីអញ្ចឹងទៅ ព្រោះថាវាញុាំអត់បាន វាមានលក្ខណៈដូចថាវា វាមិនសូវអត់ធ្មត់ទេ។ បាទ រីឯមនុស្សធំវិញ គឺគាត់មិនដឹងទេ គាត់ដឹងតែឆ្ងាញ់របស់គាត់ខ្លួនឯង គាត់ចេះតែញោចដាក់ទៅ ហើយគាត់មិនដឹងថាកូនក្មេងហ្នឹង វាចូលចិត្តម៉េច ហើយវានឹងអាចទ្រាំបានម៉េច។ បាទ ដូចខ្ញុំអញ្ចឹង កាលពេលខ្ញុំនៅអាយុ ១០ ឆ្នាំអញ្ចឹង គឺខ្ញុំនៅតែមិនទាន់ញុាំម្ទេសបានទេ ព្រោះថាខ្ញុំវាទ្រាំអត់បាន វាហឹរពេក បាទ ដូច្នេះនៅក្នុងប្រធានបទម្ហូបហឹរនេះ គឺវាទាក់ទងទៅនឹងក្មេងមួយទៀត បាទ ដូចថាកូនក្មេងមិនសូវជាញុាំម្ទេសហឹរបានប៉ុន្មានទេ។ បាទ ភាគតិចណាស់ដែលញុាំម្ទេសហឹរបាន បាទ ដូច្នេះប្រធានបទមួយនេះគឺសម្រាប់កូនក្មេង គឺយើងគួរតែស្វែងយល់ដែល ដូចថា បើសិនជា ឧទាហរណ៍ថា បើសិនជាយើងមានក្មេងញុាំជាមួយ យើងគួរតែកុំញោចម្ទេសចូលទៅខាងក្នុងទឹកសម្ល នឹងយើងគួរតែញោចម្ទេសនឹងដាក់នៅខាងក្រៅសម្លអីអញ្ចឹងទៅ បាទ ដើម្បីឲ្យកូនក្មេងនឹងងាយស្រួលក្នុងការបរិភោគ ក្នុងការញុាំអីអញ្ចឹង ក្នុងការទទួលទាន បាទ ហើយយើងនឹងក៏មានលក្ខណៈស្រួលដែរ។ យើងដួសតែទឹកត្រីមួយចានមក ហើយយើងញោចម្ទេសដាក់ចូលក្នុងនឹងទៅ បាទ ហើយយើងញុាំអញ្ចឹងទៅ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ក៏វាធ្វើឲ្យយើងមានលក្ខណៈងាយស្រួលដែរ។ យើងអាចលាយម្ទេស ឬមួយក៏លាយទឹកត្រី លាយប៊ីចេង លាយស្ករដាក់ក្នុងចានផ្សេងអញ្ចឹងទៅ ដើម្បីឲ្យវាមានលក្ខណៈងាយស្រួល។ បាទ ដូច្នេះខ្ញុំសូមបញ្ចប់នូវរូបភាព សុំទោសគឺខ្ញុំសូមបញ្ចប់ក្នុងការបកស្រាយនូវប្រធានបទម្ហូបហឹរតែត្រឹមនេះសិន បាទ សង្ឃឹមថាជួបគ្នានូវប្រធានបទក្រោយៗទៀត។ សូមអរគុណ សូមជម្រាបលា។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.